# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

លេខ ១៣៦/០៨ គ.ជ.ប

## គោលការណ៍

## សម្រាប់

## ស្ថានីយវិទ្យុ និងទូរទស្សន៍ឯកជនក្នុងការលក់ម៉ោង ឬជូលម៉ោងចាក់ផ្សាយ ឱ្យគណបក្សនយោបាយដើម្បីចាក់ផ្សាយអំពីកម្មវិធីគោលនយោបាយ ក្នុងពេលឃោសនាបោះឆ្នោត

- អនុលោមតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ ។
- អនុលោមតាមបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រជំពូកទី ៧ ស្តីពីការឃោសនាបោះឆ្នោត ។
- អនុលោមតាមគោលការណ៍ សម្រាប់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ។
- ដើម្បីធានាឱ្យដំណើរការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី ៤ ប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ស្របតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។
- ដើម្បីធានាឱ្យមានការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានស្របតាមគោលការណ៍ស្មើភាព ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានដាក់ចេញនូវគោលការណ៍សម្រាប់ស្ថានីយវិទ្យុ និងទូរទស្សន៍ឯកជន ដែលមានបំណងលក់ម៉ោង ឬជូលម៉ោងផ្សាយទៅឱ្យគណបក្សនយោបាយ ដែលបានចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនជាផ្លូវការ ត្រូវអនុវត្តដូចខាងក្រោម ។

### ១. សេចក្តីប្រកាសជាសាធារណៈ

១.១ ការឃោសនាបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី ៤ មានរយៈពេល ៣០ ថ្ងៃ ដែលប្រព្រឹត្តទៅពីថ្ងៃទី ២៦ ខែ មិថុនា ដល់ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០០៨ ។ ស្ថានីយវិទ្យុ និងទូរទស្សន៍ឯកជន ដែលមានបំណងលក់ម៉ោង ឬជូលម៉ោងផ្សាយ ត្រូវប្រកាសជាសាធារណៈអំពីចំនួនម៉ោងដែលខ្លួនមានសម្រាប់លក់ ឬជូលក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃនេះ ។

១.២ អ្នកគ្រប់គ្រងស្ថានីយវិទ្យុ និងទូរទស្សន៍ឯកជន ត្រូវប្រកាសផ្សព្វផ្សាយជាសាធារណៈ អំពីតម្លៃសមស្រប ដែល លក់ម៉ោង ឬជួលម៉ោង ។

១.៣ អ្នកគ្រប់គ្រងស្ថានីយវិទ្យុ និងទូរទស្សន៍ឯកជន ត្រូវជូនដំណឹងអំពីការលក់ម៉ោង ឬជួលម៉ោងផ្សាយនេះ មកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងជូនដំណឹងទៅគ្រប់គណបក្សនយោបាយទាំងអស់ ដែលបានចូលរួមក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ អាណត្តិទី ៤ ។

១.៤ ការជូនដំណឹងត្រូវធ្វើឡើងអោយបាន ១៥ (ដប់ប្រាំ) ថ្ងៃយ៉ាងតិច មុនថ្ងៃឃោសនាបោះឆ្នោត ។

## ២. វិធីលក់ម៉ោង ឬជួលម៉ោងឱ្យគណបក្សនយោបាយ

២.១ ការលក់ម៉ោង ឬជួលម៉ោងផ្សាយឱ្យគណបក្សនយោបាយធ្វើការផ្សព្វផ្សាយ អំពីគោលនយោបាយរបស់គណបក្សនយោបាយ ត្រូវផ្អែកទៅតាមគោលការណ៍ស្មើភាព តម្លៃស្មើៗគ្នា និងតាមលំដាប់មុនក្រោយ ។

២.២ ដើម្បីធានានូវភាពស្មើគ្នា អ្នកគ្រប់គ្រងស្ថានីយត្រូវយកចំនួនម៉ោងសរុបដែលលក់ ឬជួល ចែកជាមួយនឹងចំនួនគណបក្សនយោបាយ ដែលបានចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនជាផ្លូវការ រួចលក់តែចំណែកម៉ោង ដែលគណបក្សនយោបាយនីមួយៗទទួលបាន ។

២.៣ ប្រសិនបើមានតែគណបក្សនយោបាយមួយចំនួន ក្នុងចំណោមគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតទាំងអស់ បានទិញម៉ោងផ្សាយ ឬជួលម៉ោងផ្សាយ អ្នកគ្រប់គ្រងស្ថានីយអាចលក់ម៉ោង ឬជួលម៉ោងដែលនៅសល់នោះបន្ថែមទៅឱ្យគណបក្សនយោបាយ ដែលមានលទ្ធភាពទិញ ឬជួល បន្ថែមទៅទៀតបាន ។

២.៤ ការលក់ម៉ោងផ្សាយ ឬជួលម៉ោងផ្សាយបន្ថែម អាចធ្វើទៅបានយ៉ាងច្រើនចំនួន ៣ (បី)ដង នៃចំណែករបស់ខ្លួន ដូចមានចែងនៅក្នុងចំណុច ២.២ ខាងលើ ។

២.៥ ការលក់ម៉ោងផ្សាយ ឬជួលម៉ោងផ្សាយឱ្យគណបក្សនយោបាយ មិនត្រូវបានអនុញ្ញាតឱ្យអ្នកគ្រប់គ្រងស្ថានីយវិទ្យុ និងទូរទស្សន៍ លក់ម៉ោង ឬជួលម៉ោងផ្ដាច់មុខឱ្យគណបក្សនយោបាយណាមួយឡើយ ។

## ៣. សិទ្ធិ និងការទទួលខុសត្រូវ

៣.១ អ្នកគ្រប់គ្រងស្ថានីយវិទ្យុ និងទូរទស្សន៍ឯកជន ពុំទទួលខុសត្រូវចំពោះខ្លឹមសារឃោសនារបស់គណបក្សនយោបាយឡើយ ។

៣.២ គណបក្សនយោបាយដែលទិញម៉ោង ឬជួលម៉ោងផ្សព្វផ្សាយពីគោលនយោបាយ ត្រូវទទួលខុសត្រូវចំពោះខ្លឹមសារនៃការឃោសនារបស់ខ្លួន ។

៣.៣ អ្នកគ្រប់គ្រងស្ថានីយវិទ្យុ និងទូរទស្សន៍ ឯកជន និងគណបក្សនយោបាយ ត្រូវគោរពបទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប គោលការណ៍សម្រាប់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និងគោលការណ៍សម្រាប់ស្ថានីយវិទ្យុ និងទូរទស្សន៍ឯកជន ក្នុងការលក់ម៉ោង ឬជួលម៉ោងផ្សាយនេះ ។

៣.៤ ក្នុងករណី គ.ជ.ប រកឃើញថា ខ្លឹមសារអត្ថបទនៃការឃោសនារបស់គណបក្សនយោបាយ រំលោភលើបទបញ្ជា និងនីតិវិធី របស់ គ.ជ.ប គ.ជ.ប មានសិទ្ធិស្នើឱ្យគណបក្សនយោបាយធ្វើការកែតម្រូវ ។ ប្រសិនបើគណបក្សនយោបាយនៅតែមិនព្រមកែតម្រូវ គ.ជ.ប មានសិទ្ធិដកហូត ឬបញ្ឈប់ដោយឱ្យស្ថានីយវិទ្យុ និងទូរទស្សន៍ធ្វើការផ្សព្វផ្សាយនូវខ្លឹមសារអត្ថបទឃោសនានោះទាំងស្រុង ។

៣.៥ គ្រប់ស្ថានីយវិទ្យុ និងទូរទស្សន៍ទាំងអស់ ត្រូវបញ្ឈប់ការផ្សព្វផ្សាយទាំងស្រុងនូវព័ត៌មាន ឬ/និងការឃោសនា ដែលពាក់ព័ន្ធដល់គណបក្សនយោបាយណាមួយ ក្នុងរយៈពេល ២៤ (ម្ភៃបួន) ម៉ោង មុនថ្ងៃបោះឆ្នោត និងថ្ងៃបោះឆ្នោត ។ ក្នុងករណីប្រព្រឹត្តល្មើស និងត្រូវទទួលពិន័យតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។

ភ្នំពេញ ថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០០៨

ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

ប្រធាន

អ៊ឹម_សួស្ដី